**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអធិការកិច្ច**

លេខ: ០៥៧/២៦........អ.ធ.ក.ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតយន្តការពិនិត្យលើការទទួលពាក្យបណ្ដឹង

## រដ្ឋមន្ត្រីក្រសួងអធិការកិច្ច

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៩ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច
- បានឃើញប្រកាសលេខ ០៤០/២៥ អ.ធ.ក.ប្រ.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានដោះស្រាយបណ្ដឹង
- បានឃើញសេចក្ដីសម្រេចលេខ ០១៦/២៥ អធក.សសរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការកែសម្រួលការបង្កើតក្រុមការងារតាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ ៣៨៥៤ របស់ក្រសួងអធិការកិច្ច
- បានឃើញសេចក្ដីណែនាំលេខ០០២/២៦ ស.ណ.ន ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៦ ស្ដីពីការពង្រឹងប្រសិទ្ធភាពការងារទទួលពាក្យបណ្ដឹង របស់ក្រសួងអធិការកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអធិការកិច្ច

## សម្រេច

**ប្រការ១.-**

យន្តការពិនិត្យលើការទទួលពាក្យបណ្តឹង ត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើនការសម្របសម្រួលផ្ទៃក្នុង ដោយធានាបាននូវភាពស៊ីសង្វាក់ក្នុងចរន្តការងាររដ្ឋបាល និងលើកកម្ពស់ដំណើរការទាន់ពេលវេលានៃការទទួលពាក្យបណ្តឹង ដើម្បីពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃដំណើរការទទួលពាក្យបណ្តឹងមុននឹងបន្តនីតិវិធី។

**ប្រការ២.-**

យន្តការពិនិត្យលើការទទួលពាក្យបណ្តឹង មានភារកិច្ចនិងរបៀបរបបការងារ ដូចខាងក្រោម៖

- ពិនិត្យពិភាក្សាលើពាក្យបណ្តឹងក្នុងដំណើរការទទួលពាក្យបណ្តឹង មុននឹងមានចំណាត់ការបន្តតាមនីតិវិធី ដើម្បីពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពិនិត្យពាក្យបណ្តឹងដោយផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនិងច្បាស់លាស់នៃអង្គហេតុ កំណត់បញ្ហាបន្ទាន់ដែលត្រូវការយកចិត្តទុកដាក់ភ្លាមៗ
- ពិនិត្យបឋមលើកម្មវត្ថុនៃពាក្យបណ្តឹង អង្គហេតុ និងឯកសារពាក់ព័ន្ធនានា ឬភាពអាចទទួលយកបាននៃពាក្យបណ្តឹងទៅតាមភាពជាក់ស្តែង
- កិច្ចប្រជុំនៃយន្តការពិនិត្យលើការទទួលពាក្យបណ្តឹងត្រូវធ្វើឡើងមួយលើកក្នុងមួយសប្តាហ៍ ឬតាមភាពចាំបាច់ដែលកំណត់ដោយរដ្ឋមន្ត្រី
- កិច្ចប្រជុំនៃយន្តការពិនិត្យលើការទទួលពាក្យបណ្តឹង ត្រូវដឹកនាំដោយរដ្ឋមន្ត្រី។ ក្នុងករណីកិច្ចប្រជុំដឹកនាំដោយអនុប្រធានដែលមានការអនុញ្ញាតពីរដ្ឋមន្ត្រី លទ្ធផលនៃកិច្ចប្រជុំត្រូវដាក់ជូនរដ្ឋមន្ត្រីពិនិត្យ និងសម្រេច។ គ្រប់លទ្ធផលនៃកិច្ចប្រជុំត្រូវមានការសម្រេចពីរដ្ឋមន្ត្រី
- ការពិភាក្សាដែលធ្វើឡើងអំឡុងពេលកិច្ចប្រជុំ នឹងត្រូវរក្សាការសម្ងាត់ ហើយត្រូវកត់ត្រាទុកយ៉ាងត្រឹមត្រូវសម្រាប់គោលបំណងរដ្ឋបាលផ្ទៃក្នុង។ លទ្ធផលនៃកិច្ចប្រជុំ ត្រូវកម្រិតត្រឹមសកម្មភាពសម្របសម្រួលនីតិវិធី រួមទាំងការបញ្ជាក់ការចុះបញ្ជី ភាពត្រឹមត្រូវនិងច្បាស់លាស់នៃអង្គហេតុ និងសម្រាប់ការចាត់បញ្ជូនបន្តតែប៉ុណ្ណោះ
- ឯកសារ និងការរក្សាកំណត់ត្រាពាល់ពាក្យបណ្តឹងទាំងអស់ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងបញ្ជីផ្លូវការ ឬប្រព័ន្ធអេឡិចត្រូនិច និងកំណត់លេខបណ្តឹងតែមួយគត់។ ឯកសារពាក្យបណ្តឹងត្រូវរៀបចំជាប្រព័ន្ធ រក្សាសុវត្ថិភាពដោយឈរលើគោលការណ៍រក្សាភាពសម្ងាត់ និងគ្រប់គ្រងស្របតាមនីតិវិធីគ្រប់គ្រងកំណត់ត្រាដែលបានបង្កើតឡើង។ កំណត់ត្រាទាំងអស់ត្រូវអាចស្វែងរកបានសម្រាប់ការពិនិត្យផ្ទៃក្នុង សវនកម្ម និងការត្រួតពិនិត្យនៅពេលដែលត្រូវការ ដោយធានាបាននូវតម្លាភាព និងការទទួលខុសត្រូវពេញលេញនៅក្នុងដំណើរការទទួលពាក្យបណ្តឹង។

**ប្រការ៣.-**

កិច្ចប្រជុំនៃយន្តការពិនិត្យលើការទទួលពាក្យបណ្តឹងមានសមាសភាពចូលរួម ដូចខាងក្រោម៖

- រដ្ឋមន្ត្រី ប្រធាន
- ថ្នាក់ដឹកនាំជួយរដ្ឋមន្ត្រីលើការងារដោះស្រាយបណ្តឹងតវ៉ា ១រូប អនុប្រធាន
- ថ្នាក់ដឹកនាំជួយរដ្ឋមន្ត្រីលើការងារដោះស្រាយបណ្តឹងបរិហារ ១រូប អនុប្រធាន

- នាយកខុទ្ទកាល័យ សមាជិក
- ថ្នាក់ដឹកនាំជួយរដ្ឋមន្ត្រីលើការងារដោះស្រាយបណ្តឹងតវ៉ានិងបណ្តឹងបរិហារ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង សមាជិក
- ប្រធាននាយកដ្ឋានដោះស្រាយបណ្តឹងតវ៉ា សមាជិក
- ប្រធាននាយកដ្ឋានដោះស្រាយបណ្តឹងបរិហារ សមាជិក
- សមាសភាពមួយចំនួនទៀត តាមការចាត់តាំងរបស់រដ្ឋមន្ត្រី សមាជិក។

**ប្រការ៤.-**

ការរៀបចំនិងការសម្របសម្រួលកិច្ចប្រជុំនៃយន្តការពិនិត្យលើការទទួលពាក្យបណ្តឹង គឺជាការទទួលខុសត្រូវរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង ដែលត្រូវធានាថា កិច្ចប្រជុំត្រូវធ្វើឡើងប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាព ដោយមិនបង្កឱ្យមានការពន្យារពេលក្នុងដំណើរការជាផ្លូវការនៃពាក្យបណ្តឹងឡើយ។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន នាយកវិទ្យាស្ថានជាតិអធិការកិច្ច មន្ទីរអធិការកិច្ចរាជធានី-ខេត្តក្រោមឱវាទក្រសួង ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**សុខ សូកេន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៤ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ